**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)**

**Cambodian Water Supply Association (C.W.A)**

# កំណត់ហេតុស្តីពី
# កិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និង ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អង្គការ និងដៃគូពាក់ព័ន្ធនានាក្នុងខេត្តបន្ទាយមានជ័យ
# ស្តីពី
# «រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»

## ១. សេចក្តីផ្តើម

ថ្ងៃពុធ ៣កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៦ ក្រោមកិច្ចសហការរវាង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក្រសួង ឧ.វ.ប.ន.) ក្រសួងមហាផ្ទៃ រដ្ឋបាលខេត្តបន្ទាយមានជ័យ និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អង្គការ និងដៃគូពាក់ព័ន្ធនានា ក្នុងខេត្តបន្ទាយមានជ័យស្តីពី **«រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»** នៅ ឌឹ វ៉ាយ ផាលេស រីសត (The White Palace Resort) ខេត្តបន្ទាយមានជ័យ ឧបត្ថម្ភដោយ អង្គការ **Water.org**។

កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម តន់ សុខជា** អគ្គនាយក នៃអគ្គនាយកដ្ឋានទឹកស្អាត តំណាងឱ្យក្រសួង ឧ.វ.ប.ន. **ឯកឧត្តម ពឹម សំណាង** អនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ **ឯកឧត្តម សួន តារា** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **លោក កែ សួនសុភាព** អភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ **លោក លឹម មិញ** នាយកប្រតិបត្តិសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និង **លោក ខេង ច័ន្ទរិទ្ធ** អ្នកគ្រប់គ្រងភាពជាដៃគូនៃអង្គការ Water.org ព្រមទាំងមានការអញ្ជើញចូលរួមពី មន្ត្រីអមដំណើរនៃក្រសួង ឧ.វ.ប.ន. មន្ត្រីអមដំណើរនៃក្រសួងមហាផ្ទៃ រដ្ឋបាលខេត្ត មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកអង្គការ Water.org និងសមាគមសរុបចំនួន ៧៦ នាក់ (ស្រី ១០ នាក់)។

## ២. គោលដៅ និងគោលបំណង

កិច្ចប្រជុំពិគ្រោះយោបល់នេះមានគោលដៅ **«រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»** និងមានគោលបំណងជាក់លាក់ចំនួន ៤ ដូចខាងក្រោម៖

១. ផ្សព្វផ្សាយលិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃស្តីពី «ការជំរុញលើកកម្ពស់ និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ» ឱ្យកាន់តែមានប្រសិទ្ធភាព។

២. កំណត់បញ្ហាប្រឈមចម្បងៗ ស្វែងរកដំណោះស្រាយ និងរួមគ្នាក្នុងការធានាឱ្យមានភាពប្រសើរក្នុងការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋ។

៣. បង្កើនទំនាក់ទំនង និងកិច្ចសហការរវាងក្រសួង មន្ទីរ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការដៃគូ និងភាគីពាក់ព័ន្ធក្នុងវិស័យ ដើម្បីស្វែងរកការគាំទ្រក្នុងការឆ្លើយតបជាវិជ្ជមានទៅនឹងតម្រូវការរបស់ប្រជាជន។

៤. បង្កើនចំណេះដឹងបន្ថែមអំពីវិស័យផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ជាពិសេសច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត។

## ៣. សកម្មភាព និងលទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់

### ៣.១. កម្មវិធីបើកកិច្ចប្រជុំ

#### ក. មតិស្វាគមន៍របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

**លោក លីម មិញ** នាយកប្រតិបត្តិសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានថ្លែងស្វាគមន៍ និងអំណរគុណដល់គណៈអធិបតី និងភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់។ លោកបានលើកឡើងថា គិតត្រឹមខែមេសា ឆ្នាំ២០២៥ មានត្រឹម **៤២.១%** នៃខ្នងផ្ទះនៅកម្ពុជាទទួលបានទឹកស្អាតតាមបំពង់ប្រើប្រាស់ ក្នុងនោះវិស័យឯកជនផ្គត់ផ្គង់បាន **៥៦%**។ តាមលទ្ធផលនេះបានបង្ហាញពីតួនាទីដ៏សំខាន់របស់វិស័យឯកជនក្នុងការគាំទ្ររាជរដ្ឋាភិបាលឱ្យសម្រេចគោលដៅ SDG 6 ស្តីពីទឹកស្អាត និងអនាម័យ។

លោកបានបញ្ជាក់ថា ទោះបីវិស័យទឹកស្អាតមានការរីកចម្រើនក៏ដោយ ការគ្របដណ្តប់សេវានៅមានកម្រិតទាប ប្រតិបត្តិករបាននិងកំពុងប្រឈមនឹងបញ្ហាជាច្រើនដែលរារាំងដល់ការពង្រីកសេវាកម្ម។ ដូច្នេះ សមាគមបានរៀបចំកិច្ចប្រជុំក្រោមប្រធានបទ**«រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»** ដើម្បីផ្សព្វផ្សាយបន្ថែមលើលិខិតណែនាំលេខ ៣៣១១ សជណ កំណត់បញ្ហាប្រឈម ស្វែងរកដំណោះស្រាយរួម និងពង្រឹងកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធ។

ជាចុងក្រោយ លោកបានសម្តែងការរំពឹងថា កិច្ចប្រជុំនេះនឹងរួមចំណែកដល់ការដោះស្រាយបញ្ហាប្រឈម ពង្រឹងការសម្របសម្រួលរវាងអាជ្ញាធរ និងប្រតិបត្តិករ និងជំរុញឱ្យប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាតកាន់តែទូលំទូលាយ ព្រមទាំងថ្លែងអំណរគុណដល់ក្រសួង ឧ.វ.ប.ន. ក្រសួងមហាផ្ទៃ រដ្ឋបាលខេត្តបន្ទាយមានជ័យ និងអង្គការ Water.org ដែលបានគាំទ្រការរៀបចំកិច្ចប្រជុំនេះ។

#### ខ. ចំណាប់អារម្មណ៍របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

**លោក កែ សួនសុភាព អភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ** បានស្វាគមន៍គណៈអធិបតី និងអ្នកចូលរួមទាំងអស់ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្រោមប្រធានបទ**«រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»** និងបានបង្ហាញពីការប្តេជ្ញាចិត្តរបស់រដ្ឋបាលខេត្តក្នុងការសហការជាមួយមន្ទីរជំនាញ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីពង្រីកសេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ។

តាមរបាយការណ៍របស់មន្ទីរ ឧ.វ.ប.ន. គិតត្រឹមខែឧសភា ឆ្នាំ២០២៦ ខេត្តបន្ទាយមានជ័យមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន **៣០ មូលដ្ឋាន** ក្នុងនោះមាន **២០ មូលដ្ឋាន**ទទួលបានអាជ្ញាបណ្ណ **៣ មូលដ្ឋាន**កំពុងស្នើសុំអាជ្ញាបណ្ណ **១ មូលដ្ឋាន**ទទួលបានគោលការណ៍សិក្សាសមិទ្ធិលទ្ធភាព និងគម្រោងរបស់ក្របខណ្ឌអនុវត្តកិច្ចសន្យារចនាប្លង់ សាងសង់ ផ្គត់ផ្គង់ និងដំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (DBL) ចំនួន **៦ មូលដ្ឋាន**។

លោកបានលើកឡើងនូវបញ្ហាប្រឈមចម្បងៗដែលកើតឡើងក្នុងខេត្តបន្ទាយមានជ័យរួមមាន៖ ការប្រែប្រួលអាកាសធាតុដែលប៉ះពាល់ដល់ប្រភពទឹក គម្លាតនៃការទទួលបានសេវាទឹកស្អាតរវាងទីប្រជុំជន និងតំបន់ជនបទ និងទុនវិនិយោគរបស់ប្រតិបត្តិករមួយចំនួននៅមានកម្រិត។

ជាចុងក្រោយ លោកបានស្នើឱ្យប្រតិបត្តិករពង្រឹងពង្រីកការផ្គត់ផ្គង់ទឹកស្អាតឱ្យបានទូលំទូលាយដើម្បីឆ្លើយតបសំណូមពរប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា និងស្នើឱ្យមន្ទីរពាក់ព័ន្ធតាមដានការអនុវត្តរបស់ប្រតិបត្តិករ។ រដ្ឋបាលខេត្តនឹងបន្តគាំទ្រយ៉ាងពេញទំហឹងដល់ការអភិវឌ្ឍវិស័យទឹកស្អាត និងជំរុញការអនុវត្តតាមលិខិតណែនាំលេខ ៣៣១១ សជណ ស្តីពី«***ការជំរុញលើកកម្ពស់និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ***»។

### គ. សុន្ទរកថាគន្លឹះរបស់ក្រសួងមហាផ្ទៃ

**ឯកឧត្តម ពឹម សំណាង អនុរដ្ឋលេខាធិការ** ក្រសួងមហាផ្ទៃ បានថ្លែងសុន្ទរកថាគន្លឹះថា ដើម្បីរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានជួបប្រទះដោយប្រតិបត្តិករទឹកស្អាត និងក្នុងគោលបំណងគាំទ្រនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក្រសួងមហាផ្ទៃ បានដាក់ចេញនូវលិខិតលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ ស្តីពី ***«ការជំរុញលើកកម្ពស់និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ»*** ដែលរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។ ចំណុចសំខាន់ៗចំនួន ៥ ដែលក្រសួងមហាផ្ទៃបានធ្វើការណែនាំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយកចិត្តទុកដាក់អនុវត្ត ដូចខាងក្រោម៖

១. ត្រូវរក្សាការពារឱ្យបានគង់វង្សនូវប្រភពទឹកធម្មជាតិដែលមានស្រាប់ និងពង្រីកវិសាលភាព ឬបង្កើតនូវប្រភពទឹកថ្មីសម្រាប់ធ្វើការផ្គត់ផ្គង់ទឹកស្អាត និងការប្រើប្រាស់ផ្សេងៗឱ្យបានគ្រប់គ្រាន់នៅតាមមូលដ្ឋាន។

២. ត្រូវកៀរគរ និងលើកទឹកចិត្តដល់ផ្នែកឯកជនក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ និងផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរបស់ខ្លួនទាំងនៅទីប្រជុំជន និងតំបន់ជនបទ។

៣. ត្រូវធ្វើផែនការក្នុងការពង្រីកបណ្តាញទឹកស្អាតដើម្បីផ្គត់ផ្គង់ឆ្លើយតបទៅនឹងតម្រូវការនៃកំណើនប្រជាសាស្ត្រ និងនគរូបនីយកម្ម។

៤. ត្រូវចាត់វិធានការ និងរក្សាការពារឱ្យបានគត់មត់នូវដីចំណីផ្លូវ និងចិញ្ចើមផ្លូវដែលជាដីសាធារណៈរបស់រដ្ឋ ដើម្បីប្រើប្រាស់ជាប្រយោជន៍ក្នុងការតភ្ជាប់បណ្តាញទឹកស្អាត បណ្តាញខ្សែកាបក្រោមដី បណ្តាញលូសាធារណៈ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់បម្រើផលប្រយោជន៍សាធារណៈ។

៥. ត្រូវសហការជាមួយវិស័យឯកជន ជាពិសេសប្រតិបត្តិករទឹកស្អាតឱ្យចូលរួមក្នុងការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីអាចចែករំលែកព័ត៌មាននានាក្នុងការអភិវឌ្ឍមូលដ្ឋាន។

ជាមួយគ្នានេះដែរ **ឯកឧត្តម** បានផ្តល់អនុសាសន៍បន្ថែមថា រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រុង/ស្រុក និងឃុំ/សង្កាត់) ត្រូវយកចិត្តទុកដាក់អនុវត្តខ្លឹមសារនៃលិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ ស្តីពី ***«ការជំរុញលើកកម្ពស់ និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ»*** ឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត មន្ទីរ/អង្គភាពពាក់ព័ន្ធ និងភាគីពាក់ព័ន្ធនានា ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមក្នុងវិស័យទឹកស្អាត។ ជាមួយគ្នានេះ អ្នកចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ទាំងអស់ ត្រូវផ្សព្វផ្សាយចំណេះដឹង និងព័ត៌មានដែលទទួលបានពីកិច្ចប្រជុំនេះបន្តទៅកាន់សហការី និងអ្នកពាក់ព័ន្ធក្នុងអង្គភាពរបស់ខ្លួន ដើម្បីជំរុញការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព។

### ឃ. សុន្ទរកថាបើកកិច្ចប្រជុំ

**ឯកឧត្តម តន់ សុខជា** អគ្គនាយក **នៃអគ្គនាយកដ្ឋានទឹកស្អាត** ក្រសួង ឧ.វ.ប.ន. បង្ហាញថា **ឯកឧត្តម** ពិតជាមានសេចក្តីរំភើបរីករាយ ដោយទទួលបានការប្រគល់ភារកិច្ចដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ហេម វណ្ណឌី រដ្ឋមន្ត្រី** ក្រសួង ឧ.វ.ប.ន. មកចូលរួមដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងដៃគូពាក់ព័ន្ធ ក្នុងខេត្តបន្ទាយមានជ័យ លើប្រធានបទស្តីពី**«រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»**។ **ឯកឧត្តម** បានថ្លែងអំណរគុណចំពោះក្រសួងមហាផ្ទៃ និងរដ្ឋបាលខេត្តបន្ទាយមានជ័យ ដែលបានឆ្លើយតបក្នុងការសម្របសម្រួល និងចាត់បញ្ជូនសមាសភាពជាតំណាងចូលរួម ព្រមទាំងបានបង្កលក្ខណៈឱ្យមន្ទីរ អង្គភាពពាក់ព័ន្ធនានាក្នុងខេត្ត និងរដ្ឋបាលក្រុង/ស្រុក នៃខេត្តបន្ទាយមានជ័យ បានមកចូលរួមក្នុងកិច្ចប្រជុំនេះ។

ទន្ទឹមនេះ ខ្ញុំសូមអរគុណចំពោះអង្គការ Water.org ដែលជាដៃគូដ៏សំខាន់ក្នុងការគាំទ្រ ឧបត្ថម្ភកម្មវិធីប្រជុំ និងអរគុណផងដែរ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងអ្នកពាក់ព័ន្ធដទៃទៀតដែលបានមកចូលរួម។

**ឯកឧត្តម** បានលើកឡើងពីយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់វិស័យអាទិភាព គន្លឹះចំនួន៥ គឺ **«មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា»** ដែលក្នុងនោះ **«ទឹក»** គឺត្រូវបានវិកិលមកជាអាទិភាពលំដាប់ទី៣ ដោយផ្តោតលើរបៀបវារៈ**«ធានាប្រសិទ្ធភាពសមិទ្ធកម្ម»**និងអភិក្រម«ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ជំរុញឱ្យសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ (SDG 6) ដែលកំណត់ថា **«ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានសាកលកម្ម និងសមធម៌នូវទឹកបរិភោគ ដែលមានសុវត្ថិភាព និងថ្លៃសមរម្យ សម្រាប់ប្រជាជនទាំងអស់»** ហើយការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតត្រូវឈរលើគោលការណ៍ នៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាតដែលបានកំណត់លក្ខខណ្ឌគោល **៤ យ៉ាង** គឺទឹកស្អាតត្រូវមាន **គុណភាព សុវត្ថិភាព និរន្តរភាព** និង**ថ្លៃសមរម្យ**។ ទឹកស្អាតជួយទ្រទ្រង់ទាំងសុខភាពសាធារណៈ សុខុមាលភាពសង្គម និងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច។

**ឯកឧត្តម** បានបង្ហាញអំពីវឌ្ឍនភាពនៃប្រតិបត្តិករទឹកស្អាតឯកជនដែលបានចូលរួមប្រមាណ ៣៦% ក្នុងបរិមាណនៃការផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស ហើយត្រូវបានចាត់ទុកជាដៃគូយុទ្ធសាស្ត្រសំខាន់របស់រាជរដ្ឋាភិបាល។ **ឯកឧត្តម** បានលើកឡើងថា ការអនុវត្តនៅមានបញ្ហាប្រឈមជាច្រើនដែលត្រូវបន្តខិតខំដោះស្រាយដូចជា៖ ការទទួលបានសេវាទឹកស្អាតតាមប្រព័ន្ធបណ្តាញទូទាំងប្រទេស ពុំទាន់ឆ្លើយតបទៅនឹងតម្រូវការ និងកំណើនប្រជាជនក៏ដូចជាសន្ទុះនៃកំណើននគរូបនីយកម្ម និងការរីកលូតលាស់នៃឧស្សាហកម្មនៅឡើយ។ ប្រតិបត្តិករទឹកស្អាតឯកជនមួយចំនួនដែលកំពុងចូលរួមផ្តល់សេវាទឹកស្អាតនៅមានសមត្ថភាពបច្ចេកទេស ហិរញ្ញវត្ថុ និងកម្រិតអនុលោមភាពនៅមានកម្រិត។ បញ្ហាប្រឈមដ៏មួយទៀតគឺ ប្រភពទឹកសម្រាប់ការធានានិរន្តរភាពដល់ការផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិត ឬខ្វះខាតធ្ងន់ធ្ងរនៅរដូវប្រាំង (ប្រជែងនឹងការបូមទឹកដាក់ស្រែប្រាំង) ហើយនិន្នាការនេះបន្តកើនឡើងក្នុងបរិបទបម្រែបម្រួលអាកាសធាតុនាពេលបច្ចុប្បន្ន និងអនាគត។ មួយវិញទៀត ការរងផលប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតពីការអភិវឌ្ឍនានា ដូចជាការអភិវឌ្ឍផ្លូវថ្នល់ជាដើម បាននិងកំពុងបណ្តាលឱ្យមានការចំណាយរាប់សិបលានដុល្លារ សម្រាប់ការវិនិយោគឡើងវិញ នៅលើទីតាំងដដែលៗ។ ក្រសួង ឧ.វ.ប.ន. បានពន្លឿនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ដោយផ្តល់អាទិភាពវិនិយោគលើតំបន់ដែលមានតម្រូវការប្រើប្រាស់ទឹកខ្ពស់ និងមានសក្តានុពលសេដ្ឋកិច្ច ដើម្បីពង្រីកការផ្គត់ផ្គង់ទឹកស្អាត គាំទ្រការអភិវឌ្ឍឧស្សាហកម្ម កសិ-ឧស្សាហកម្ម និងលើកកម្ពស់បរិយាកាសវិនិយោគ។ ទន្ទឹមនឹងនេះ ក្រសួងក៏ជំរុញការចូលរួមរបស់វិស័យឯកជនតាមយន្តការ «ភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)» សម្រាប់តំបន់ដែលមិនទាន់មានភាពទាក់ទាញផ្នែកសេដ្ឋកិច្ច និងបានណែនាំឱ្យប្រតិបត្តិករទាំងអស់រៀបចំផែនការរយៈពេលមធ្យម ដើម្បីឆ្លើយតបបញ្ហា និងតម្រូវការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព។

ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមមួយចំនួនដូចបានលើកឡើងខាងលើ និងដើម្បីធ្វើឱ្យប្រទេសយើងសម្រេចបានវឌ្ឍនភាព និងសមិទ្ធផលថ្មីៗក្នុងវិស័យទឹកស្អាត ជាការចាំបាច់ណាស់គឺត្រូវមានការចូលរួមប្រកបដោយភាពបុរេសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការ សមាគម ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងផ្នែកពាក់ព័ន្ធ។ ច្បាស់ណាស់ថា កិច្ចសហការ និងការគាំទ្រនេះ នឹងធ្វើឱ្យប្រជាពលរដ្ឋយើងទទួលផលប្រយោជន៍ពីវិស័យទឹកស្អាត ដើម្បីលើកកម្ពស់សុខុមាលភាព ជីវភាពរស់នៅ និងបង្កើតជាផលជះដល់ការរីកលូតលាស់នៃសង្គម សេដ្ឋកិច្ច។៕

**ឯកឧត្តម** ប្រធានអង្គប្រជុំ ក៏បានថ្លែងនូវការគោរពអរគុណសាជាថ្មី ចំពោះ **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានដាក់ចេញការណែនាំចំនួន ៥ ចំណុច (ដូចមានបញ្ជាក់ខាងលើ) ដល់ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីចូលរួមគាំទ្រ និងជំរុញការអភិវឌ្ឍវិស័យទឹកស្អាតសម្រាប់ជាឧត្តមប្រយោជន៍របស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅមូលដ្ឋាន។

## ៣.២. បទបង្ហាញអំពី«ច្បាប់ស្ដីពីការគ្រប់គ្រងទឹកស្អាត»

**លោក សឿន យុត្តិរ៉ា** អនុប្រធាននាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត នៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧ.វ.ប.ន. បានធ្វើបទបង្ហាញអំពី**«ច្បាប់ស្ដីពីការគ្រប់គ្រងទឹកស្អាត»** ដែលមានមាតិកាសំខាន់ៗរួមមាន៖ ១).តើអ្វីទៅជាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត? ២).សមត្ថកិច្ចគ្រប់គ្រងវិស័យទឹកស្អាត ៣).សិទ្ធិមូលដ្ឋានរបស់ប្រតិបត្តិករទឹកស្អាត ៤).កាតព្វកិច្ចរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ៥).ការដោះស្រាយវិវាទ ៦).មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត ៧).សមាគមអ្នកផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត និង ៨).ទោសប្បញ្ញត្តិ។

## ៣.៣. បទបង្ហាញអំពី«លិខិតណែនាំលេខ ៣៣១១ សជណ»និង«តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល»

**ឯកឧត្តម សួន តារា អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល** ក្រសួងមហាផ្ទៃ បានធ្វើបទបង្ហាញអំពីចំណុចសំខាន់ៗអំពីច្បាប់រៀបចំអង្គការ ផ្ដោតលើ«តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល» និងលិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ ស្ដីពី«ការជំរុញលើកកម្ពស់និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ»៖

១. **ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ៖**
   - **មាត្រា ២០៖** ក្រុមប្រឹក្សានីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
   - **មាត្រា ៣៧៖** ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល។
   - **មាត្រា ៣៨៖** ការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ៖ ប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេងទៀត ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា។

២. **ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់៖**
   - **ជំពូកទី ៦៖** ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
     - **មាត្រា ៦០៖** ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។
     - **មាត្រា ៦១៖** ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ។

៣. **អនុក្រឹត្យលេខ ២១៩. អនក្រ. បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

– **ជំពូកទី ២៖** គោលការណ៍រួមនៃការរៀបចំផែនការអភិវឌ្ឍន៍ និងវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

  - **មាត្រា ៥៖** ការរៀបចំផែនការអភិវឌ្ឍន៍ និងវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រព្រឹត្តទៅតាមគោលការណ៍រួម ដូចជា៖ ការចែករំលែកព័ត៌មាន តម្លាភាព សង្គត់ភាព និងសុខដុមនីយកម្ម ការចូលរួមពិគ្រោះយោបល់ជាទូទៅ ការឆ្លើយតបនឹងតម្រូវការ គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ប្រសិទ្ធភាព និងសុក្រិតភាពសេដ្ឋកិច្ច និងសង្គម ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន និងការធានាសមធម៌។

៤. លិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ ស្ដីពី ***«ការជំរុញលើកកម្ពស់និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ»៖***

- **គោលបំណង៖** ដើម្បីចូលរួមចំណែកធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់ និងការផ្ដល់សេវាទឹកស្អាតនៅមូលដ្ឋានឱ្យកាន់តែមានភាពល្អប្រសើរប្រកបដោយអនាម័យ ថ្លៃសមរម្យ និងមាននិរន្តរភាពស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែលបានកំណត់វិស័យអាទិភាពគន្លឹះចំនួន៥ គឺ **«មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា»** សំដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅមូលដ្ឋាន។
- **គោលដៅ៖** រដ្ឋបាលរាជធានី ខេត្ត ត្រូវជំរុញលើកកម្ពស់និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតក្នុងដែនរដ្ឋបាលរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។
- ***ភារកិច្ច ឬសកម្មភាពសំខាន់ៗដែលត្រូវអនុវត្ត៖***

  ១. ត្រូវរក្សាការពារឱ្យបានគង់វង្សនូវប្រភពទឹកធម្មជាតិដែលមានស្រាប់ និងពង្រីកវិសាលភាព ឬបង្កើតនូវប្រភពទឹកថ្មីសម្រាប់ធ្វើការផ្គត់ផ្គង់ទឹកស្អាត និងការប្រើប្រាស់ផ្សេងៗឱ្យបានគ្រប់គ្រាន់នៅតាមមូលដ្ឋាន។

  ២. ត្រូវកៀរគរ និងលើកទឹកចិត្តដល់ផ្នែកឯកជនក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ និងផ្ដល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរបស់ខ្លួនទាំងនៅទីប្រជុំជន និងតំបន់ជនបទ។

  ៣. ត្រូវធ្វើផែនការក្នុងការពង្រីកបណ្ដាញទឹកស្អាតដើម្បីផ្គត់ផ្គង់ឆ្លើយតបទៅនឹងតម្រូវការនៃកំណើនប្រជាសាស្ត្រ និងនគរូបនីយកម្ម។

  ៤. ត្រូវចាត់វិធានការ និងរក្សាការពារឱ្យបានគត់មត់នូវដីចំណីផ្លូវ និងចិញ្ចើមផ្លូវដែលជាដីសាធារណៈរបស់រដ្ឋ ដើម្បីប្រើប្រាស់ជាប្រយោជន៍ក្នុងការតភ្ជាប់បណ្ដាញទឹកស្អាត បណ្ដាញខ្សែកាបក្រោមដី បណ្ដាញលូសាធារណៈ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់បម្រើផលប្រយោជន៍សាធារណៈ។

  ៥. ត្រូវសហការជាមួយវិស័យឯកជន ជាពិសេសប្រតិបត្តិករទឹកស្អាតឱ្យចូលរួមក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីអាចចែករំលែកព័ត៌មាននានាក្នុងការអភិវឌ្ឍមូលដ្ឋាន។

## ៣.៤. បទបង្ហាញអំពីបញ្ហារបស់ប្រតិបត្តិករទូទៅ និងប្រតិបត្តិករនៅខេត្តបន្ទាយមានជ័យ

**លោក លឹម មិញ** នាយកប្រតិបត្តិសមាគម បានធ្វើបទបង្ហាញពីបច្ចុប្បន្នភាពអំពីសមាគម និងបញ្ហាប្រឈមទូទៅរបស់សមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងជាពិសេសប្រតិបត្តិករនៅខេត្តបន្ទាយមានជ័យ។

*តារាងទី ១ - សង្ខេបអំពីបញ្ហាប្រឈម និងសំណូមពរ របស់ប្រតិបត្តិករ នៅខេត្តបន្ទាយមានជ័យ*

| ល.រ | បញ្ហាប្រឈមរបស់ប្រតិបត្តិករ | សំណូមពរ |
|---|---|---|
| ១ | កង្វះប្រភពទឹកសម្រាប់ផលិតទឹកស្អាតនៅរដូវប្រាំង។<br>(៩/១៣ ស្ថានីយ) | ➢ ក្រសួង/មន្ទីរធនធានទឹក និងឧតុនិយម ជួយសម្របសម្រួលចំពោះបញ្ហាខ្វះប្រភពទឹក។<br>➢ សំណូមពរដល់រដ្ឋបាលឃុំភូមិថ្មី ក្នុងការស្តារស្រះសហគមន៍កាប់ចោរ ដើម្បីធានាឱ្យបានប្រភពទឹកគ្រប់គ្រាន់ សម្រាប់ផលិត និងចែកចាយទៅកាន់ប្រជាជនទាំងអស់ក្នុងតំបន់អាជ្ញាបណ្ណ។<br>➢ ស្នើសុំស្ថាប័នពាក់ព័ន្ធជួយសម្របសម្រួលបើកទ្វារទឹក ដើម្បីបង្ហូរទឹកចូលស្ទឹងស្រែងបន្ថែម។<br>➢ សំណូមពរដល់មន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ ក្នុងការគ្រប់គ្រងទឹក និងបើកទឹកជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដែលជាវិស័យអាទិភាព។<br>➢ ស្នើសុំស្ថាប័នពាក់ព័ន្ធជួយដាក់បញ្ចូលបរិមាណទឹកដែលត្រូវការទឹកសម្រាប់អាជីវកម្មផលិតទឹកស្អាត។<br>➢ ស្នើសុំការយោគយល់ពីប្រជាជនក្នុងតំបន់អាជ្ញាបណ្ណរបស់ក្រុមហ៊ុនថេបអេហ្វិក ឯ.ក (ដែលមានទីតាំងនៅភូមិតាសល់ ឃុំគោកបល្ល័ង្គ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ) ក្នុងការដំឡើងថ្លៃលក់ទឹក (បន្តិចបន្តួច) ដើម្បីទ្រទ្រង់នឹងការចំណាយ ទៅលើការវិនិយោគបន្ថែមសម្រាប់ប្រភពទឹករួមមាន៖ ការអេភិវឌ្ឍដី និងជីកស្រះ សម្រាប់រក្សាទឹក។ បន្ទាប់ពីជីកស្រះបាន ១០០% ក្រុមហ៊ុនរំពឹងថា នឹងអាចផលិត និងចែកចាយដល់ប្រជាជន ២៤/២៤ម៉ោង។ |
| ២ | ខូចខាតបណ្តាញបំពង់ទឹកស្អាតដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ថ្នល់ លូ បង្គោលអគ្គិសនី<br>(៧/១៣ ស្ថានីយ) | ➢ សំណូមពរដល់មន្ទីរពាក់ព័ន្ធ ជួយសម្របសម្រួលជាមួយក្រុមហ៊ុនធ្វើផ្លូវ ក្នុងការផ្តល់ព័ត៌មាន និងសំណងចំពោះការខូចខាតដល់បណ្តាញបំពង់ទឹកស្អាត។<br>➢ សំណូមពរដល់រដ្ឋបាលភូមិ ឃុំ ចែករំលែកពីគម្រោងវិនិយោគភូមិ ឃុំ ជាពិសេសគម្រោងពង្រីកផ្លូវ។<br>➢ សំណូមពរដល់រដ្ឋបាលភូមិ ឃុំ ជួយសម្របសម្រួល ជាមួយក្រុមហ៊ុនសាងសង់ ដើម្បីដោះស្រាយផលប៉ះពាល់។<br>➢ ស្នើសុំរដ្ឋបាលឃុំគួរពិចារណាទៅលើកញ្ចប់ថវិកាសម្រាប់ផលប៉ះពាល់បណ្តាញបំពង់ទឹកស្អាត នៅពេលដែលក្រុមហ៊ុនសាងសង់ដាក់ដេញថ្លៃ។<br>➢ សូមឱ្យអាជ្ញាធរជួយផ្តល់ដំណឹងជាមុនយ៉ាងតិចមួយខែ ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់បណ្តាញទឹកស្អាត។<br>➢ ស្នើសុំដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ជួយកំណត់បង្ហាញទីតាំងសមស្របសម្រាប់ការរាយបណ្តាញបំពង់ទឹកស្អាត។ |

| ល.រ | បញ្ហាប្រឈមរបស់ប្រតិបត្តិករ | សំណូមពរ |
|---|---|---|
| ៣ | ខូចខាតបណ្ដាញបំពង់ទឹកស្អាត ដោយសារសកម្មភាពរបស់ប្រជាពលរដ្ឋ (ជីក ភ្ជួរដីប៉ះបណ្ដាញ និងពេលខ្លះគាត់មិនរាយការណ៍)។ (៧/១៣ ស្ថានីយ) | ➢ ស្នើសុំរដ្ឋបាលឃុំជួយផ្សព្វផ្សាយដល់ប្រជាជនចូលរួមការពារ និងមានការប្រុងប្រយ័ត្នក្នុងពេលជីកដីធ្វើរបង ឬសាងសង់។ ➢ ស្នើសុំរដ្ឋបាលឃុំជួយណែនាំដល់ប្រជាជនជួយរាយការណ៍អំពីការលេចធ្លាយបំពង់ទឹកស្អាតទៅភូមិ ឃុំ ឬទាក់ទងមកស្ថានីយទឹកស្អាតដោយផ្ទាល់។ ➢ ស្នើសុំឱ្យប្រជាពលរដ្ឋជួយផ្ដល់ដំណឹងអំពីការលេចធ្លាយមកស្ថានីយឱ្យបានទាន់ពេលវេលា។ ➢ ស្នើសុំឱ្យក្រុមហ៊ុនអគ្គិសនីមានការប្រុងប្រយ័ត្ន និងសូមផ្ដល់ដំណឹងមកស្ថានីយទឹកស្អាត នៅពេលដាំបង្គោលអគ្គិសនី។ |
| ៤ | ប្រជាពលរដ្ឋធ្វើសំណង់រំលោភលើដីចំណីផ្លូវធ្វើឱ្យពិបាកក្នុងការដាក់បណ្ដាញ។ (២/១៣ ស្ថានីយ) | ➢ សូមអាជ្ញាធរជួយណែនាំដល់ប្រជាពលរដ្ឋពីការប្រើប្រាស់ដីចំណីផ្លូវ។ ➢ សូមអាជ្ញាធរជួយផ្សព្វផ្សាយ និងសម្រួលក្នុងការដាក់បណ្ដាញបំពង់ទឹកស្អាតលើដីចំណីផ្លូវ។ |
| ៥ | ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសេវាផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិត នាំឱ្យការប្រើប្រាស់ទឹកស្អាតក្នុងបរិមាណតិចតួច និងការភ្ជាប់បណ្ដាញទឹកស្អាតមានកម្រិតទាបនៅឡើយ។ (៤/១៣ ស្ថានីយ) | ➢ ស្នើសុំអាជ្ញាធរមូលដ្ឋានជួយពន្យល់ ជំរុញ និងផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត។ |
| ៦ | តំបន់គ្មានសក្ដានុពលក្នុងការពង្រីកបណ្ដាញ (១/១៣ ស្ថានីយ) | ➢ ស្នើសុំក្រសួង និងមន្ទីរ ឧ.វ.ប.ន. ជួយពិនិត្យមើលលទ្ធភាពជួយស្វែងរកដៃគូនានាក្នុងការផ្ដល់ទុនពង្រីកទៅកាន់តំបន់គ្មានសក្ដានុពល។ |

## ៣.៥. វេទិកាពិភាក្សា និងសំណួរ ចម្លើយ

**លោក លឹម មិញ** បានសម្របសម្រួលកិច្ចពិភាក្សា និងកម្មវិធីសំណួរ ចម្លើយដូចខាងក្រោម៖

*តារាងទី ២ - សង្ខេបអំពីកិច្ចពិភាក្សា*

| សំណួរ/មតិយោបល់/សំណូមពរ | មតិយោបល់ឆ្លើយតប/សំណូមពរ |
|---|---|
| **លោក សាយ ញឹប ម្ចាស់ស្ថានីយទឹកស្អាតមង្គលបុរី៖** ១. តើហេតុអ្វីបានជាសំណើសុំអាជ្ញាបណ្ណឆ្លងកាត់តែរដ្ឋបាលឃុំ/សង្កាត់ ដោយមិនឆ្លងកាត់រដ្ឋបាលស្រុក/ក្រុង និងខេត្ត មុនបញ្ជូនទៅមន្ទីរ និងក្រសួងឧ.វ.ប.ន.? | **ឯកឧត្តម អគ្គនាយក បានឆ្លើយជូនដូចខាងក្រោម៖** – **សេវាផ្គត់ផ្គង់ទឹកស្អាត** គឺជាសេវាសាធារណៈមូលដ្ឋាន ដែលអាចផ្សារភ្ជាប់ជាមួយផែនការវិនិយោគរយៈពេលបីឆ្នាំរំកិលរបស់រដ្ឋបាលឃុំ/សង្កាត់។ – **រដ្ឋបាលឃុំ/សង្កាត់** មានភារកិច្ចផ្ដល់មូលវិចារលើសំណើសុំធ្វើការសិក្សារបស់ប្រតិបត្តិករ ដែលជាការវាយតម្លៃលើសមត្ថភាព ភាពជឿទុកចិត្តធនធាន និងអត្តចរិតរបស់វិនិយោគិនដែលស្នើសុំធ្វើអាជីវកម្ម។ – **រដ្ឋបាលឃុំ/សង្កាត់** គឺជាអាជ្ញាធរដែលស្ថិតនៅជិតប្រជាពលរដ្ឋ និងប្រតិបត្តិករជាងគេ ហើយមានការយល់ដឹងច្បាស់អំពីស្ថានភាពជាក់ស្ដែង តម្រូវការរបស់ប្រជាពលរដ្ឋ និងសក្ដានុពលអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។ – **ការកំណត់បែបបទ និងនីតិវិធីនេះ** មានគោលបំណងសម្រួលដល់វិនិយោគិនក្នុងការវិនិយោគលើវិស័យទឹកស្អាតនៅមូលដ្ឋាន ព្រមទាំងពង្រឹងតួនាទី |

| សំណួរ/មតិយោបល់/សំណូមពរ | មតិយោបល់ឆ្លើយតប/សំណូមពរ |
|---|---|
| | សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ/សង្កាត់ ក្នុងការគ្រប់គ្រង និងតាមដានការផ្តល់សេវាទឹកស្អាតជាសេវាសាធារណៈដែលប្រជាពលរដ្ឋប្រើប្រាស់ជាប្រចាំ។<br>– **ស្របតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណ** ប្រតិបត្តិករមានកាតព្វកិច្ចរៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាមួយរដ្ឋបាលឃុំ/សង្កាត់ ដើម្បីរាយការណ៍អំពីលទ្ធផលប្រតិបត្តិការ បញ្ហាប្រឈម និងផែនការអភិវឌ្ឍន៍ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។ |
| **លោក ឌិត ឋី អ្នកគ្រប់គ្រងស្ថានីយទឹកស្អាតទឹកជោរមានជ័យ៖**<br>២. ប្រតិបត្តិករមួយចំនួនមិនដែលទទួលបានការជូនដំណឹងអំពីការសាងសង់ ឬជួសជួលផ្លូវថ្នល់ជាមុននោះទេ ដែលបណ្តាលឱ្យខូចខាតបណ្តាញបំពង់ទឹកស្អាត ដោយគ្មានសំណង និងកិច្ចសហការជាមួយក្រុមហ៊ុនម៉ៅការសាងសង់ឡើយ។ | **ឯកឧត្តម អគ្គនាយក បានឆ្លើយជូនដូចខាងក្រោម៖**<br>– ដោយសារច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ទើបតែត្រូវបានអនុម័តឱ្យប្រើប្រាស់នៅឆ្នាំ២០២៣ ការយល់ដឹង និងការផ្សព្វផ្សាយនៅមានកម្រិតនៅឡើយ។ ដូច្នេះច្បាប់នេះត្រូវការពេលវេលាបន្ថែមសម្រាប់ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹង ហើយក្រសួងឧ.វ.ប.ន. កំពុងបន្តបញ្ចូលខ្លឹមសារច្បាប់នេះទៅក្នុងកម្មវិធី និងសកម្មភាពផ្សព្វផ្សាយពាក់ព័ន្ធទាំងអស់។<br>– សូមឱ្យស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ បង្កើនការយល់ដឹងអំពីច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។<br>– ស្នើសុំក្រសួងមហាផ្ទៃ ជួយណែនាំ និងជំរុញរដ្ឋបាលរាជធានី-ខេត្ត ឱ្យជូនដំណឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីផែនការអភិវឌ្ឍន៍នៅមូលដ្ឋាន និងចែករំលែកព័ត៌មានជាមួយប្រតិបត្តិករទឹកស្អាត ដើម្បីពង្រឹងកិច្ចសហការ និងគាំទ្រការរៀបចំផែនការវិនិយោគ។<br>– សូមឱ្យប្រតិបត្តិករធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយបញ្ហាប្រឈមនានា ជាពិសេសពាក់ព័ន្ធនឹងការសាងសង់ ឬជួសជុលផ្លូវថ្នល់ ដែលអាចប៉ះពាល់ដល់បណ្តាញផ្គត់ផ្គង់ទឹកស្អាត។<br>– សូមឱ្យប្រតិបត្តិករតាមដាន និងយកចិត្តទុកដាក់ចំពោះផែនការ និងសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋាន ព្រមទាំងរក្សាការទំនាក់ទំនងជាប្រចាំជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលបានព័ត៌មានថ្មីៗ និងអាចរៀបចំផែនការប្រតិបត្តិការបានទាន់ពេលវេលា។<br>– ចំពោះការទាមទារសំណង ក្រសួងមិនអាចអនុវត្តជំនួសប្រតិបត្តិករបានទេ ព្រោះមានតែម្ចាស់ទ្រព្យសម្បត្តិប៉ុណ្ណោះដែលមានសិទ្ធិទាមទារសំណងតាមផ្លូវច្បាប់។ ក្នុងករណីមានការខូចខាតបណ្តាញផ្គត់ផ្គង់ទឹកស្អាត ប្រតិបត្តិករគួរតែស្នើសុំដី ការក្សាការពារជាបន្ទាន់ ដើម្បីបញ្ឈប់សកម្មភាពដែលបង្កការខូចខាត និងអនុវត្តតាមមាត្រា ២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត។ ប្រតិបត្តិករមានសិទ្ធិការពារទ្រព្យសម្បត្តិរបស់ខ្លួនដែលកំពុងបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ហើយសូមឱ្យអាជ្ញាធរមូលដ្ឋានជួយសម្របសម្រួល និងគាំទ្រការអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព។<br>**តំណាងមន្ទីរសាធារណការ និងដឹកជញ្ជូន បានចូលរួមយោបល់៖**<br>– ស្នើសុំឱ្យគ្រប់ភាគីពាក់ព័ន្ធ បង្កើនកិច្ចសហការ និងសម្របសម្រួលឱ្យបានជិតស្និទ្ធ ដើម្បីបង្ការ និងកាត់បន្ថយការខូចខាតបណ្តាញបំពង់ទឹកស្អាត។ |

| សំណួរ/មតិយោបល់/សំណូមពរ | មតិយោបល់ឆ្លើយតប/សំណូមពរ |
|---|---|
| | **តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ បានចូលរួមយោបល់ថា ៖**<br>– រាល់គម្រោងអភិវឌ្ឍន៍ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួង/មន្ទីរអភិវឌ្ឍន៍ជនបទ តែងតែត្រូវបានជូនដំណឹង និងផ្សព្វផ្សាយជាមុនដល់អាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធ ដើម្បីសម្របសម្រួលការអនុវត្ត។<br>– ចំពោះប្រព័ន្ធផ្គត់ផ្គង់ទឹកសហគមន៍ ក៏មានការកប់បណ្តាញបំពង់ក្រោមដីដូចគ្នា ហើយក៏ជួបប្រទះបញ្ហាប្រឈមពីការខូចខាតបណ្តាញ ដែលបង្កឡើងដោយសកម្មភាពសាងសង់ ឬជួសជុលផ្លូវថ្នល់ផងដែរ។ ការខូចខាតទាំងនេះបានប៉ះពាល់ដល់ទ្រព្យសម្បត្តិសាធារណៈ និងបណ្តាលឱ្យមានការចំណាយថវិការដ្ឋ និងមូលនិធិឃុំក្នុងការជួសជុល និងស្តារឡើងវិញ។<br>– ស្នើសុំឱ្យក្រសួង/មន្ទីរពាក់ព័ន្ធ បន្តពង្រឹងកិច្ចសហការ និងសម្របសម្រួលក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ ដើម្បីកាត់បន្ថយការខូចខាត និងធានាប្រសិទ្ធភាពនៃការអនុវត្តគម្រោងអភិវឌ្ឍន៍។<br>**នាយកប្រតិបត្តិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានស្នើសុំ៖**<br>– ឱ្យគ្រប់ស្ថាប័ន និងអង្គភាពដែលអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា ជូនដំណឹងជាមុនដល់មន្ទីរឧ.វ.ប.ន. និងប្រតិបត្តិករទឹកស្អាត ដើម្បីចូលរួមពិនិត្យ សិក្សា វាយតម្លៃ និងរៀបចំវិធានការបង្ការ និងកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានលើបណ្តាញ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត មុនពេលចាប់ផ្តើមអនុវត្តគម្រោង។<br>**ឯកឧត្តម អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ បានចូលរួម៖**<br>– ក្រសួងមហាផ្ទៃបានចេញសៀវភៅណែនាំស្តីពីបទដ្ឋានបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងរាជធានី/ខេត្ត ដែលបានណែនាំឱ្យមានការសិក្សា និងវាយតម្លៃផលប៉ះពាល់នានាជាមុន ព្រមទាំងដាក់បញ្ចូលវិធានការដោះស្រាយផលប៉ះពាល់ទាំងនោះក្នុងឯកសារដេញថ្លៃ និងការអនុវត្តគម្រោង។<br>– សរុបមក ដើម្បីកាត់បន្ថយផលប៉ះពាល់ឱ្យនៅកម្រិតអប្បបរមា យើងចាំបាច់ត្រូវអនុវត្តវិធានការសំខាន់ៗចំនួន ៣ រួមមាន៖ (១) ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹង (២) ការពង្រឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ និង (៣) ការដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍។ |
| **រដ្ឋបាលមង្គលបុរី៖**<br>៣. តើទឹកស្អាតតាមបំពង់ត្រូវបានត្រួតពិនិត្យគុណភាពដោយរបៀបណា?<br>៤. តើមន្ទីរ ឧ.វ.ប.ន. បានចុះត្រួតពិនិត្យគុណភាព និងគ្រប់គ្រងអាជីវកម្មទឹកសុទ្ធ ដោយរបៀបណា? | **លោក ពេជ្រ សម្បត្តិរតនៈ អនុប្រធាននាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង បានជម្រាបជូនថា៖**<br>– ប្រតិបត្តិករត្រូវអនុលោមតាមស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិរបស់ក្រសួង ឧ.វ.ប.ន. ដែលមានកាតព្វកិច្ចធ្វើតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃលើ ៥ ប៉ារ៉ាម៉ែត្រ (ប៉េហាស ភាពល្អក់ ពណ៌ទឹក សារធាតុរឹងរលាយសរុប និងក្លរសំណល់សម្លាប់មេរោគ) និងផ្ញើសំណាកមកតេស្តនៅមន្ទីរពិសោធន៍ជាតិរៀងរាល់ត្រីមាស និងប្រចាំឆ្នាំ លើប៉ារ៉ាម៉ែត្រសំខាន់ៗ ដែលជាតម្រូវការ។<br>**លោកប្រធានមន្ទីរ ឧ.វ.ប.ន. ខេត្តបន្ទាយមានជ័យ៖**<br>– អាជីវកម្មផលិតទឹកបរិសុទ្ធត្រូវអនុវត្តនីតិវិធីស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មពីមន្ទីរមានសមត្ថកិច្ច ដោយត្រូវឆ្លងកាត់ការចុះពិនិត្យ និងវាយតម្លៃទីតាំង |

| សំណួរ/មតិយោបល់/សំណូមពរ | មតិយោបល់ឆ្លើយតប/សំណូមពរ |
|---|---|
| | ព្រមទាំងគុណភាពប្រភពទឹកឱ្យបានច្បាស់លាស់។ ទោះជាយ៉ាងណា កន្លងមកនៅមានអាជីវកម្មមួយចំនួនដែលមិនបានស្នើសុំការអនុញ្ញាតតាមនីតិវិធីកំណត់។<br>– សូមអាជ្ញាធរមូលដ្ឋានបន្តសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរមានសមត្ថកិច្ចក្នុងការពិនិត្យ តាមដាន និងចាត់វិធានការតាមច្បាប់ចំពោះអាជីវកម្មផលិតទឹកបរិសុទ្ធដែលគ្មានការអនុញ្ញាតត្រឹមត្រូវ ឬមិនគោរពតាមស្តង់ដារអនាម័យ និងបទប្បញ្ញត្តិជាធរមាន។ |
| **លោក សាយ ញ៉ឹប ម្ចាស់ស្ថានីយទឹកស្អាតមង្គលបុរី៖**<br>៥. ស្នើសុំរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមដោះស្រាយជាបន្ទាន់ចំពោះការខ្វះប្រភពទឹកសម្រាប់ផលិតទឹកស្អាត។ | **តំណាងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តបន្ទាយមានជ័យបានជម្រាបជូនថា៖**<br>– ករណីស្ទឹងស្រែងដែលមានប្រភពទឹកនៅខេត្តឧត្តរមានជ័យ៖ កន្លងមកមន្ទីរតែងសហការក្នុងការបិទបើកទ្វារទឹក។ ការស្នើសុំបើកទ្វារទឹកមានពីរដំណាក់កាល៖ (១) សហគមន៍ស្នើសុំតាមរយៈឃុំ/សង្កាត់ ស្រុក រួចមកមន្ទីរ (២) មន្ទីរឯកភាព រួចស្នើសុំបន្តទៅរដ្ឋបាលខេត្តឧត្តរមានជ័យ ដើម្បីបើកទ្វារទឹកនេះ។<br>– ករណីស្ទឹងមង្គលបុរី៖ ប្រជាជនប្រើប្រាស់ប្រភពទឹកស្ទឹងនេះធ្វើកសិកម្មនៅផ្នែកខាងលើ ដែលនាំឱ្យខ្វះប្រភពទឹកខ្លាំង។ មន្ទីរបានចុះត្រួតពិនិត្យស្ទឹងផ្នែកខាងលើដែរ ប៉ុន្តែនៅផ្នែកខាងលើនេះក៏ខ្វះទឹកដែរ។ សម្រាប់ស្ទឹងសិរីសោភ័ណមិនសូវមានបញ្ហាប្រឈមនោះទេ ដោយសារយើងមានអាងទឹកចំនួនពីរនៅខាងលើ។<br>– ចំពោះផែនការមេសម្រាប់ស្ទឹងមង្គលបុរី និងស្ទឹងសិរីសោភ័ណរបស់មន្ទីរបានដាក់ស្នើទៅក្រសួងធនធានទឹក និងឧតុនិយមរួចហើយដែរ និងកំពុងរង់ចាំការឆ្លើយតបពីក្រសួង។ នៅឆ្នាំនេះគម្រោង AFD នឹងស្តារស្ទឹងស្វាយចេក។<br>– នៅដើមខែនេះ មន្ត្រីបច្ចេកទេសរបស់ក្រសួងបានចុះមកសិក្សាអំពីស្ថានភាពប្រភពទឹកផងដែរ។<br>– សំណូមពរទៅអាជ្ញាធរមូលដ្ឋាន សូមជួយគ្រប់គ្រង និងទប់ស្កាត់ការកាន់កាប់ដីចំណីអាងទឹក ព្រោះប្រជាពលរដ្ឋដែលអាស្រ័យផលលើដីចំណីអាងខ្លះបង្កជាផលវិបាកច្រើន។<br>**ឯកឧត្តមអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃបានចូលរួមថា៖**<br>– យោងតាមនីតិវិធីនៃការរៀបចំផែនការវិនិយោគ សូមស្នើឱ្យរដ្ឋបាលឃុំសង្កាត់/ផ្តល់អាទិភាពដល់ការអភិវឌ្ឍវិស័យទឹកស្អាត និងដាក់បញ្ចូលវិស័យនេះក្នុងផែនការវិនិយោគរយៈពេលបីឆ្នាំរំកិល និងផែនការអភិវឌ្ឍរបស់ខ្លួនស្របតាមតម្រូវការ និងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន។ |
| **លោក លឹម មិញ នាយកប្រតិបត្តិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា៖**<br>៦. ក្នុងករណីមានការជាន់តំបន់អាជ្ញាបណ្ណរវាងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសហគមន៍ និងប្រតិបត្តិករទឹកស្អាតឯកជន ភាគីពាក់ព័ន្ធគួរសហការគ្នាដោះស្រាយដោយផ្អែកលើផលប្រយោជន៍របស់ប្រជាពលរដ្ឋជាចម្បង។ ជម្រើសអាទិភាពគឺការពិភាក្សា | **តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ៖**<br>– ចំពោះកញ្ចប់ថវិកាដែលទទួលបានពីដៃគូអភិវឌ្ឍន៍ ឬម្ចាស់មូលនិធិ ការអនុវត្តគម្រោងត្រូវអនុលោមតាមគោលបំណង សូចនាករ និងលក្ខខណ្ឌដែលបានកំណត់ដោយម្ចាស់មូលនិធិ។ ដូច្នេះ មន្ទីរត្រូវអនុវត្តសកម្មភាពស្របតាមលក្ខខណ្ឌ និងកាតព្វកិច្ចដែលបានព្រមព្រៀង។<br>– កន្លងមក មន្ទីរអភិវឌ្ឍន៍ជនបទ មិនបានអនុវត្តគម្រោងដែលជាន់តំបន់អាជ្ញាបណ្ណរបស់ប្រតិបត្តិករទឹកស្អាតឯកជននោះទេ។ ការអនុវត្តគម្រោង |

| សំណួរ/មតិយោបល់/សំណូមពរ | មតិយោបល់ឆ្លើយតប/សំណូមពរ |
|---|---|
| ជាមួយប្រតិបត្តិករទឹកស្អាតដែលមានអាជ្ញាបណ្ណ ដើម្បីស្វែងរកយន្តការគាំទ្រ ឬការពង្រីកបណ្ដាញសេវាដែលអាចផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋប្រកបដោយនិរន្តរភាព ជាជាងការប្រើប្រាស់ថវិកាបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកសហគមន៍ថ្មីនៅក្នុងតំបន់ដែលមានអាជ្ញាបណ្ណរួចហើយ។<br>៧. ក្នុងករណីដែលចាំបាច់ត្រូវសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសហគមន៍ថ្មី មន្ទីរអភិវឌ្ឍន៍ជនបទគួរពិភាក្សា និងសម្របសម្រួលជាមួយមន្ទីរ ឧ.វ.ប.ន. ឱ្យបានច្បាស់លាស់ជាមុន ដើម្បីធានាបាននូវការឯកភាពគ្នា និងបញ្ចៀសការកើតមានជម្លោះ ឬបញ្ហាប្រឈមនានានាពេលអនាគត។ | ភាគច្រើនផ្ដោតលើការកែលម្អលទ្ធភាពទទួលបានទឹកប្រើប្រាស់តាមរយៈការជីកស្រះ ការជីកអណ្ដូង និងការផ្ដល់ធុង ឬពាងស្ដុកទឹកជាដើម។ |

## ៣.៦. កម្មវិធីបិទកិច្ចប្រជុំពិគ្រោះយោបល់

### ក. ចំណាប់អារម្មណ៍ចំពោះកិច្ចប្រជុំពិគ្រោះយោបល់

**ឯកឧត្តម ពឹម សំណាង** **អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** បានមានប្រសាសន៍ថា បន្ទាប់ពីបានស្ដាប់មតិ និងកិច្ចពិភាក្សាពីគ្រប់ភាគីពាក់ព័ន្ធពេញមួយថ្ងៃ **ឯកឧត្តម** សង្កេតឃើញថា បញ្ហាប្រឈមភាគច្រើនកើតឡើងដោយសារការសម្របសម្រួល និងកិច្ចសហការរវាងភាគីពាក់ព័ន្ធមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់។ ក្នុងន័យនេះ **ឯកឧត្តម** បានផ្ដល់អនុសាសន៍ដល់រដ្ឋបាលក្រុង/ស្រុក និងរដ្ឋបាលឃុំ/សង្កាត់ ដូចខាងក្រោម៖

១. ត្រូវចូលរួមការពារ និងលើកកម្ពស់ផលប្រយោជន៍សាធារណៈ និងប្រជាពលរដ្ឋជាអាទិភាព។
២. ត្រូវជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវលិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ ស្ដីពី«**ការជំរុញលើកកម្ពស់និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ**»។
៣. ត្រូវបង្កើនកិច្ចសហការជាមួយប្រតិបត្តិករទឹកស្អាត ក្នុងការការពារ និងទប់ស្កាត់ការខូចខាតបណ្ដាញបំពង់ទឹកស្អាត ដែលជាហេដ្ឋារចនាសម្ព័ន្ធបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ។ **ឯកឧត្តម** បានគូសបញ្ជាក់ថា «**សូមធ្វើការអភិវឌ្ឍទាំងព្រម និងសូមកុំអភិវឌ្ឍមួយ បំផ្លាញមួយទៀត**» និងបានស្នើឱ្យអាជ្ញាធរពាក់ព័ន្ធចាត់វិធានការតាមច្បាប់ជាធរមាន ចំពោះបុគ្គល ឬក្រុមណាដែលបំផ្លាញទ្រព្យសម្បត្តិសាធារណៈ។

**ឯកឧត្តម** បានជូនពរដល់គណៈអធិបតី រដ្ឋបាលខេត្តបន្ទាយមានជ័យ រដ្ឋបាលក្រុង/ស្រុក មន្ទីរពាក់ព័ន្ធ អង្គការ Water.org ប្រតិបត្តិករ និងសមាគម សូមជួបតែសិរីសួស្ដី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសូមវិលត្រឡប់វិញជាមួយនឹងសេចក្ដីសុខសុវត្ថិភាព និងសុខភាពល្អ។

### ខ. សុន្ទរកថាបិទកិច្ចប្រជុំពិគ្រោះយោបល់

**ឯកឧត្តម តន់ សុខដា អគ្គនាយក** នៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧ.វ.ប.ន. បានថ្លែងអំណរគុណចំពោះអង្គការ Water.org ដែលឧបត្ថម្ភឱ្យមានកម្មវិធីនេះឡើង និងអរគុណ ក្រសួងមហាផ្ទៃ រដ្ឋបាលខេត្តបន្ទាយមានជ័យ រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ មន្ទីរពាក់ព័ន្ធ ប្រតិបត្តិករ និងសមាគមដែលបានរៀបចំ និងចូល

រួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នេះ។ **ឯកឧត្តម** បានកោតសរសើរចំពោះការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈមដែលបានលើកឡើង។ ជាការកត់សម្គាល់នៅពេលដែលយើងបានជួបជជែកគ្នាគ្រប់ភាគី យើងឃើញថា បញ្ហាខ្លះអាចនឹងងាយដោះស្រាយ ប៉ុន្តែយើងមិនបានជួប និងជជែកគ្នាកន្លងមក។

រាជរដ្ឋាភិបាលបានបង្កើតយន្តការជាច្រើន ដើម្បីដោះស្រាយបញ្ហាប្រឈមនានា រួមមាន៖

១. **គណៈកម្មាធិការជាតិគ្រប់គ្រងអាងទន្លេ** គឺជាស្ថាប័នថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយក្រសួងធនធានទឹក និងឧតុនិយម និងមានរចនាសម្ព័ន្ធចាប់ពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានឯកឧត្តម/លោកជំទាវ អភិបាលខេត្ត ជាប្រធាន។

២. **គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត** គឺជាយន្តការថ្នាក់ក្រោមជាតិដែលដឹកនាំដោយ អភិបាលរាជធានី-ខេត្ត ដើម្បីសម្របសម្រួលបញ្ហាកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងអាជ្ញាធរពាក់ព័ន្ធ។

៣. **ក្រុមការងារបច្ចេកទេសទឹកស្អាត និងអនាម័យថ្នាក់ខេត្ត** គឺជាយន្តការថ្នាក់ក្រោមជាតិ ដែលដឹកនាំដោយមន្ទីរអភិវឌ្ឍន៍ជនបទ សហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ ដូចជាមន្ទីរ ឧ.វ.ប.ន. និងដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិ លើការងារផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យ។

៤. **វេទិកាសាធារណៈ** គឺជាយន្តការផ្លូវការ ឬកម្មវិធីសន្ទនាបើកចំហមួយ ដែលរៀបចំឡើងដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋជួបផ្ទាល់ជាមួយអាជ្ញាធរ មន្ត្រីរដ្ឋាភិបាល ឬអ្នកពាក់ព័ន្ធ។ ចំពោះបញ្ហាជីចំណីផ្លូវជាបញ្ហាដែលកើតឡើងដដែលៗ

ជាថ្មីម្តងទៀត **ឯកឧត្តម** បានផ្តល់អនុសាសន៍មួយចំនួនដល់អង្គប្រជុំដូចខាងក្រោម៖

១. ស្នើឱ្យភាគីពាក់ព័ន្ធទាំងអស់ ធ្វើការពិភាក្សា និងសម្របសម្រួលគ្នាដោយស្មារតីស្ថាបនា នៅពេលមានបញ្ហាកើតឡើង ដើម្បីស្វែងរកដំណោះស្រាយរួមដែលមានតុល្យភាព និងផ្តល់ផលប្រយោជន៍ដល់គ្រប់ភាគី។

២. រដ្ឋបាលឃុំ/សង្កាត់ មានតួនាទី និងសមត្ថកិច្ចសំខាន់ក្នុងការគ្រប់គ្រង និងអភិវឌ្ឍមូលដ្ឋាន។ ដូច្នេះ ភាគីពាក់ព័ន្ធគួរពង្រឹងកិច្ចសហការ និងរក្សាការទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋបាលឃុំ/សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

៣. ប្រតិបត្តិករទឹកស្អាតគួររៀបចំកិច្ចប្រជុំជាប្រចាំជាមួយរដ្ឋបាលឃុំ/សង្កាត់ និងអ្នកប្រើប្រាស់សេវា ដើម្បីផ្លាស់ប្តូរព័ត៌មាន ស្វែងយល់អំពីផែនការអភិវឌ្ឍន៍នៅមូលដ្ឋាន និងរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាដែលអាចកើតមាន។

៤. ការផលិតទឹកបរិសុទ្ធស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួង/មន្ទីរឧ.វ.ប.ន.។ ក្នុងករណីមានការរាយការណ៍អំពីអាជីវកម្មដែលមិនគោរពតាមបទប្បញ្ញត្តិ ឬមិនទាន់មានលិខិតអនុញ្ញាតត្រឹមត្រូវ មន្ទីរមានសមត្ថកិច្ចអាចចុះត្រួតពិនិត្យទីតាំងជាក់ស្តែង និងរាយការណ៍ជូនក្រសួង ព្រមទាំងជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ។ ប្រសិនបើការត្រួតពិនិត្យបង្ហាញថា អាជីវកម្មនោះមិនទាន់បំពេញតាមលក្ខខណ្ឌច្បាប់ មន្ទីរអាចស្នើឱ្យផ្អាកសកម្មភាពអាជីវកម្មជាបណ្តោះអាសន្ន និងធ្វើការវាយតម្លៃលើគ្រប់ទិដ្ឋភាពពាក់ព័ន្ធ រួមមានផ្នែកបច្ចេកទេស អនាម័យ សុវត្ថិភាព និងផលប៉ះពាល់ដល់សហគមន៍។ ករណីលទ្ធផលវាយតម្លៃបង្ហាញថាអាជីវកម្មបានបំពេញតាមលក្ខខណ្ឌ និងស្តង់ដារកំណត់រួចរាល់ មន្ទីរនឹងណែនាំឱ្យម្ចាស់អាជីវកម្មបំពេញនីតិវិធីស្នើសុំលិខិតអនុញ្ញាត ដើម្បីដំណើរការអាជីវកម្មស្របតាមច្បាប់។

៥. ចំពោះបញ្ហាប្រភពទឹក ប្រតិបត្តិករមានសិទ្ធិក្នុងការដកយកប្រភពទឹកពីប្រភពធម្មជាតិដើម្បីផលិតទឹកស្អាត ប៉ុន្តែត្រូវសុំការអនុញ្ញាតទៅតាមបទដ្ឋានគតិយុត្ត។ ក្នុងករណីខ្វះខាតប្រភពទឹក អាជ្ញាធរមូលដ្ឋានត្រូវ

កំណត់អាទិភាពនៃការប្រើប្រាស់ទឹក និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ ដើម្បីសម្រេចជម្រើសដែលសមស្របបំផុត។

៦. អាជ្ញាធរថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ខិតខំអនុវត្តឱ្យអស់លទ្ធភាពតាមលិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ ស្តីពី *«ការជំរុញលើកកម្ពស់និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត នៅរដ្ឋបាលថ្នាក់ក្រោមជាតិ»* ដែលមាន ៥ ចំណុចសំខាន់ៗ ដែលបានពិភាក្សាគ្នាយ៉ាងផុសផុល ដើម្បីសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលនៅឆ្នាំ២០៣០។

មុននឹងបញ្ចប់ **ឯកឧត្តម** បានថ្លែងអំណរគុណចំពោះ **ឯកឧត្តម ពឹម សំណាង** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងសហការី ដែលបានចូលរួមប្រជុំពេញមួយថ្ងៃ ព្រមទាំងបានផ្តល់អនុសាសន៍ណែនាំល្អៗ ដល់កិច្ចប្រជុំ លោក លោកស្រីអញ្ជើញមកពីរដ្ឋបាលខេត្តបន្ទាយមានជ័យ រដ្ឋបាលក្រុង/ស្រុក រដ្ឋបាលឃុំ/សង្កាត់ មន្ទីរពាក់ព័ន្ធ ប្រតិបត្តិករ អង្គការ Water.org និងសមាគម និងអរគុណដល់អង្គការ Water.org ដែលតែងតែយកចិត្តទុកដាក់គាំទ្រដល់ការអភិវឌ្ឍទឹកស្អាតនៅកម្ពុជា។

កិច្ចប្រជុំពិគ្រោះយោបល់ត្រូវបានបញ្ចប់ដោយជោគជ័យនៅវេលាម៉ោង ៤:៣០ ល្ងាច នៅក្នុងថ្ងៃខែឆ្នាំដដែល ប្រកប ដោយបរិយាកាសរីករាយ ស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់៕ ✓

ថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦
**អ្នកធ្វើរបាយការណ៍**

**តូច សុគន្ធា**
អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់

**ជ. នាយកប្រតិបត្តិ**
**នាយិកាស្តីទី**

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
ស.ទ.ក
C.W.A
Cambodian Water Supply Association

**ស៊ឹម បូនិច**